# អ្នកនាំសារ
## The Messenger

45

ថ្ងៃទី ១-១៥ ខែមេសា ឆ្នាំ២០០៧- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ



# ស្ថានភាពកុមារអនាថា និងការតស៊ូក្នុងជីវិត



អំណរសប្បាយ នឹងសមិទ្ធផលថ្មី

ទំព័រ ៩



សាកល្បងក្នុង ការចិញ្ចឹមកង្កែប

ទំព័រ ១១

របាំសន្តិភាព

ទំព័រ ១០

## ស្វែងយល់ពីប្រទេសកម្ពុជា


Photo: DR

តើព្រះរាជាណាចក្រកម្ពុជាស្ថិតនៅតំបន់ណា? មានព្រំប្រទល់ជាប់ប្រទេសណាខ្លះ?

ចម្លើយ : ព្រះរាជាណាចក្រកម្ពុជាស្ថិតនៅក្នុងទ្វីបអាស៊ីភាគអាគ្នេយ៍ ហើយមានព្រំប្រទល់ជាប់នឹងប្រទេសដូចជា ខាងកើតជាប់នឹងប្រទេសវៀតណាម ខាងជើងជាប់នឹងប្រទេសឡាវ និងថៃ ខាងលិចជាប់នឹងប្រទេសថៃ និងខាងត្បូងជាប់នឹងប្រទេសវៀតណាម និងឈូងសមុទ្រថៃ។

តើព្រះរាជាណាចក្រកម្ពុជាមានប៉ុន្មានខេត្ត-ក្រុង? គឺអ្វីខ្លះ?

ចម្លើយ : ព្រះរាជាណាចក្រកម្ពុជាមានខេត្តចំនួន២០ និងក្រុង ចំនួន៤។ ខេត្ត-ក្រុងទាំងនោះមានដូចជា ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកណ្ដាល ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តបាត់ដំបង រាជធានីភ្នំពេញ ក្រុងកែប ក្រុងប៉ៃលិន និងក្រុងព្រះសីហនុ។

តើមានខេត្តក្រុងណាខ្លះដែលជាប់ព្រំប្រទល់នឹងប្រទេសវៀតណាម?

ចម្លើយ : ខេត្តដែលមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម មានខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តតាកែវ និងខេត្តកំពត។

តើខេត្តណាខ្លះមានព្រំប្រទល់ជាប់នឹងបឹងទន្លេសាប?

ចម្លើយ : នៅជុំវិញបឹងទន្លេសាប មានដូចជាខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តកំពង់ធំ។

អ្នកនាំសារ



## ថ្ងៃបុណ្យចម្លង (ថ្ងៃអាទិត្យ ទី០៨ មេសា ឆ្នាំ២០០៧)

**“លោកយេស៊ូដែលបងប្អូនបានឆ្កាង ព្រះជាម្ចាស់បានតែងតាំងលោកជាព្រះអម្ចាស់ និងជាព្រះគ្រីស្ត”**

នេះជាសេចក្ដីសង្ខេបនៃជំនឿរបស់ក្រុមគ្រីស្តទូតពីដើម! សូមប្រយ័ត្នឱ្យមែនទែន កាលយើងនិយាយថា “ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ” កុំស្មានថា លោកយេស៊ូគ្រាន់តែមានសាច់ និងឆ្អឹង ដូចលោកមានកាលពីពេលមុនប៉ុណ្ណោះឱ្យសោះ! គឺលោកយេស៊ូទទួលនូវព្រះជន្មថ្មីដ៏រុងរឿង ដែលជាព្រះជន្មផ្ទាល់ និងជាសិរីរុងរឿងនៃព្រះជាម្ចាស់។ លោកពោរពេញដោយវិញ្ញាណនៃព្រះជាម្ចាស់។ លោកយេស៊ូជាមនុស្សដូចយើងបេះបិទ។ លោកស្លាប់សែនអាម៉ាស់ និងសែនវេទនា តែឥឡូវលោកទទួលឋានៈស្មើនឹងព្រះជាម្ចាស់។ នៅក្នុងគម្ពីរ មានចែងថា លោកយេស៊ូ“គង់ខាងស្ដាំព្រះបិតា” បានសេចក្ដីថា គឺលោកមានឋានៈស្មើព្រះជាម្ចាស់។ ហេតុនេះហើយបានជាយើងហ៊ានប្រកាសថា លោកយេស៊ូជាព្រះអម្ចាស់ និងក៏ជាព្រះគ្រីស្ត! យើងបានសេចក្ដីសុខសាន្តដ៏ពិតប្រាកដ។ ក្នុងគម្ពីរភាសាដើម គ្មានចែងពាក្យ“រស់ឡើងវិញ” ទេ តែមានចែងវិញថា “ព្រះជាម្ចាស់ប្រោសលោកយេស៊ូឱ្យក្រោកពីចំណោមមនុស្សស្លាប់” “បានតើនលោកយេស៊ូឱ្យភ្ញាក់ឡើង” និង“បានលើកលោកយេស៊ូឡើង”។ល។



ដូច្នេះយើងមានសេចក្ដីសង្ឃឹម បើយើងផ្ញើជីវិតទាំងស្រុងលើព្រះយេស៊ូ ជាមនុស្សដូចយើង ដែលទទួលព្រះជន្មថ្មីដ៏រុងរឿង យើងមុខនឹងទទួលព្រះជន្មថ្មីដែរ!។ ពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងបានរួមស្លាប់-រស់ ជាមួយព្រះយេស៊ូដែលសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង។ ទុក្ខលំបាករបស់យើងសព្វថ្ងៃ អាចក្លាយជាសិរីរុងរឿងរួមជាមួយព្រះយេស៊ូដែរ។

## ថ្ងៃអាទិត្យបុណ្យចម្លងទី២ (ថ្ងៃទី ១៥ មេសា ឆ្នាំ២០០៧)

**“អ្នកណាជឿដោយឥតបានឃើញសោះ អ្នកនោះមានសុភមង្គលហើយ”**

យើងចង់បានភស្តុតាងអំពីព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង។ យើងចេះតែឆ្ងល់ព្រោះយើងមើលព្រះអង្គមិនឃើញទេ ជាពិសេសនៅពេលមានទុក្ខ ឬក៏គ្រោះកាចអ្វីមួយ យើងឆ្ងល់ថា ម្ដេចក៏ព្រះយេស៊ូមិនជួយ? តើមានព្រះជាម្ចាស់ពិតប្រាកដ ឬយ៉ាងណា? តាមពិតអ្នកដែលជឿលើព្រះយេស៊ូ គ្មានភស្តុតាងទេ គឺគេសុខចិត្តផ្ញើជីវិតលើព្រះអង្គ។ ជំនឿលើព្រះយេស៊ូជាព្រះអម្ចាស់ប្លែកពីចំណេះដឹង។

លោកថូម៉ាសគឺជាកូនភ្លោះ។ លោកយ៉ូហានចែងដូច្នេះ ជានិមិត្តរូបចង់ពន្យល់ថា លោកថូម៉ាសស្មាន ថាលោកយេស៊ូដែលទទួលជីវិតថ្មីដ៏រុងរឿង មានសាច់មានឈាមដូចលោកយេស៊ូដែលរស់នៅ។ ហេតុនេះហើយបានជាលោកចង់“ស្ទាប” ចង់“ពាល់” និងចង់“ឃើញ”! ប៉ុន្តែព្រះយេស៊ូសុំឱ្យគាត់មានជំនឿ ដោយគ្រាន់តែស្ដាប់ក្រុមសាវ៉ក ឬក៏ស្ដាប់ព្រះអង្គប៉ុណ្ណោះ។ ជួនកាលយើងពិតជាប្អូនភ្លោះរបស់លោកថូម៉ាសដែរ គឺស្មានថា យើងអាច“ឃើញ” និងអាច“យល់” ព្រះយេស៊ូដែលទទួលព្រះជន្មថ្មីដ៏រុងរឿង ប៉ុន្តែទាំងសាវ៉កទាំងយើងនឹង “ឃើញ” និង“ស្ទាប” ព្រះអង្គដោយសារតែជំនឿប៉ុណ្ណោះ។

លោកយ៉ូហានរៀបរាប់ពីក្រុមសាវ៉ក“ឃើញ”ព្រះយេស៊ូ ដោយប្រើនិមិត្តរូបជាច្រើន គឺព្រះយេស៊ូប្លែកពីមុនបានជាព្រះអង្គយាងចូលក្នុងបន្ទប់គេនៅ (គឺនៅក្នុងចិត្តគំនិតគេ) ដោយមិនបាច់បើកទ្វារទេ។ ព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឱ្យគេ ជាឫទ្ធានុភាព និងជាព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់ ឱ្យគេអាចបន្តបេសកកម្មរបស់ព្រះអង្គក្នុងលោកនេះបាន។ សេចក្ដីទាំងនេះសុទ្ធតែជានិមិត្តរូប ពន្យល់ពីរបៀបព្រះយេស៊ូដែលទទួលព្រះជន្មថ្មីដ៏រុងរឿង និងគង់នៅជាមួយយើងសព្វថ្ងៃ។



សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា!





## តើមានរូបអ្វីសម្រាប់លេខនេះ...?



កសិករកំពុងលីកណ្ដាប់ស្រូវដែលទើបច្រូតរួចយកទៅទុកដាក់។ គាត់រីករាយក្នុងចិត្ត ព្រោះទីបំផុត ការងាររបស់គាត់បានទទួលផ្លែផ្កាដោយគាត់អាចប្រមូលផលស្រូវបានបន្ទាប់ពីមានការព្យាយាមពេញមួយរដូវវស្សារួចមកនោះ



ក្មេងៗឃ្វាលគោដែលជាផ្នែកមួយនៃការងារប្រចាំថ្ងៃនៅស្រុកស្រែចំការ។ ពួកគេហាក់ដូចជាអស់កម្លាំង ក៏មកសម្រាកលេងនៅមុខចេតិយ គាប់ជួននឹងមានអ្នកមកថតរូបពួកគេ ធ្វើឱ្យពួកគេរីករាយផង និងដូចជាអៀនៗផង





លើ : ជីវភាពសិស្សសាលាជនបទ បន្ទាប់ពីចេញពីរៀន ក៏ឈរជជែកគ្នាលេង បង្កើតជាបរិយាកាសមិត្តភាពដ៏មានតម្លៃ
ស្ដាំ : សិស្សតម្បាញនៅព្រះសហគមន៍ចំការទៀង ខេត្តតាកែវ

Photographed by L. Sovanna

នេះជាសាររបស់ លោកអគ្គរាជទូតតំណាងសម្ដេចប៉ាប សាលវ៉ាទ័រ ពេណ្ណាសុីអូ ជូនគ្រីស្តបរិស័ទក្នុងឱកាសបុណ្យចម្លងនាឆ្នាំនេះ

# កុំខ្លាចអី!


Photo: S. Philong

ចូរកុំខ្លាចអី! ព្រះអម្ចាស់របស់យើងគង់នៅជាមួយយើងគ្រប់ពេលវេលាទាំងអស់។ យើងគឺជាសាក្សីនៃសេចក្ដីស្រលាញ់ ហើយក៏ជាសាក្សីនៃសេចក្ដីសង្ឃឹមផងដែរ។

បុណ្យចម្លងមានអត្ថន័យថា សេចក្ដីសង្ឃឹម។ ព្រះយេស៊ូផ្ដល់កម្លាំងឱ្យយើងដើម្បីធ្វើជាសាក្សីនៃសេចក្ដីស្រឡាញ់។ ក្នុងសប្ដាហ៍ពិសិដ្ឋនេះ ជាពិសេសថ្ងៃព្រហស្បតិ៍ពិសិដ្ឋ ថ្ងៃសុក្រពិសិដ្ឋ និងថ្ងៃសៅរ៍ពិសិដ្ឋ រហូតដល់ថ្ងៃបុណ្យចម្លង គឺជាប្រវត្តិសាស្ត្រនៃការសង្គ្រោះ ដែលព្រះយេស៊ូត្រូវរងទុក្ខលំបាក និងសោយទិវង្គតនៅលើឈើឆ្កាងរហូតដល់ពេលដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង។

ចំណែកសារលិខិតរបស់សម្ដេចប៉ាបបេណេឌីក ទី១៦ ក្នុងរដូវអប់រំពិសេសនេះ ក៏បានដាស់តឿនយើងឱ្យសំឡឹងមើលព្រះយេស៊ូដែលជាប់នៅលើឈើឆ្កាង។ តាមរយៈទុក្ខលំបាករបស់ព្រះអង្គ យើងអាចជម្រះចិត្ត និងរៀបចំខ្លួនធ្វើជាសាក្សីរបស់ព្រះយេស៊ូ ដែលព្រះអង្គមានព្រះបន្ទូលថា កុំខ្លាចអី! ខ្ញុំនៅជាមួយអ្នករាល់គ្នាជានិច្ច។

នៅស្ទើរគ្រប់ទីកន្លែង ជាពិសេសនៅក្នុងទីក្រុងភ្នំពេញ យើងសង្កេតឃើញ នៅតែមានក្មេងអនាថា ក្មេងរើសសំរាម និងក្មេងសុំទានជាច្រើន។ នៅក្នុងឆ្នាំ២០០១ បើតាមអង្គការសហប្រជាជាតិ បានធ្វើការវាយតម្លៃថា នៅលើពិភពលោកទាំងមូល ចំនួនក្មេងរស់នៅតាមចិញ្ចើមថ្នល់ ដែលមានអាយុពី៣-១៨ឆ្នាំ មានការកើនឡើងជារៀងរាល់ថ្ងៃ។ ប្រមាណជា៤០% នៃក្មេងទាំងនោះ គឺគ្មានផ្ទះស្នាក់នៅ ហើយ៦០%ទៀតធ្វើការដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។ តាមប្រភពមួយចំនួនទៀត បានធ្វើការប៉ាន់ប្រមាណថា ចំនួនទាំងនេះនឹងមានការកើនឡើងទៅដល់ ៨០០លាននាក់ នៅឆ្នាំ២០២០។

# ស្ថានភាពកុមារអនាថា និងការតស៊ូក្នុងជីវិត



Photo: L. Sovanna

ក្មេងអនាថារើសារ៉ាស្បែកជើងរកចំនួលបន្តិចបន្តួចដើម្បីផ្គត់ផ្គង់ជីវភាព



Photo: L. Sovanna

រូបខ្ញុំកើតមកក្រីក្រ រស់នៅដោយសារគំនរសំរាម មិនដឹងជាមាននរណាអាចកែប្រែអនាគតខ្ញុំឱ្យភ្លឺថ្លាប្រសើរជាងនេះទេ

## តើក្មេងតាមចិញ្ចើមថ្នល់មានន័យដូចម្តេច?

បើយោងតាមអត្ថន័យរបស់អង្គការ UNICEF បានឱ្យនិយមន័យផ្សេងៗគ្នា ទៅតាមប្រភេទនៃក្មេងតាមចិញ្ចើមថ្នល់ដូចតទៅ: ក្មេងៗដែលរស់នៅតាមចិញ្ចើមថ្នល់គឺជាក្មេង ដែលផ្តាច់ទំនាក់ទំនងជាមួយឪពុកម្តាយរបស់គេ ហើយរស់នៅតែម្នាក់ឯងនៅតាមផ្លូវ។ នៅក្នុងទីក្រុងភ្នំពេញគឺមានប្រហែលជា១២០០នាក់ ដែលនៅរស់តាមផ្លូវ ដែលមាន២០ភាគរយជាក្មេងស្រី និងភាគច្រើនមានអាយុពី១២-១៨ឆ្នាំ។ ក្មេងៗធ្វើការនៅតាមផ្លូវ ជាក្មេងដែលចំណាយពេលវេលារបស់ពួកគេទាំងប៉ុន្មាន ឬភាគច្រើននៃពេលវេលារបស់ពួកគេ ទៅធ្វើការនៅតាមផ្លូវដើម្បីជួយបង្កើនចំណូលដល់គ្រួសារ ឬមួយក៏សម្រាប់ខ្លួនរបស់ពួកគេផ្ទាល់តែម្តង។ ក្មេងៗទាំងនេះ មានផ្ទះដើម្បីត្រឡប់ទៅស្នាក់នៅវិញ ជារឿយៗ ពួកគេមិនដេកនៅតាមផ្លូវនោះទេ។ នៅក្នុងទីក្រុងភ្នំពេញ មាន១០០០០ទៅ២០០០០នាក់ ដែលមាន ៥០ភាគរយ គឺជាក្មេងស្រី និងភាគច្រើន មានអាយុពី៦-១៥ឆ្នាំ។ ក្មេងៗដែលមានគ្រួសាររស់នៅតាមផ្លូវ ជាក្មេងដែលរស់នៅជាមួយគ្រួសាររបស់ពួកគេតាមផ្លូវ។ នៅទីក្រុងភ្នំពេញ មានពី៥០០-១៥០០នាក់។

## ស្ថានភាពកុមារអនាថានៅប្រទេសកម្ពុជា

បើតាមប្រវត្តិសាស្ត្រប្រទេសកម្ពុជា មានភាពច្របូកច្របល់ ដែលបានបន្សល់ទុកជាកេរតំណែល នៃបញ្ហាសង្គមជាច្រើន ដោយបូកបញ្ចូលទាំងចំនួនក្មេងដែលរស់នៅ និងធ្វើការនៅតាមផ្លូវដ៏ច្រើនលើសលប់ផងដែរ។ តាមរបាយការណ៍ ដែលបានដកស្រង់ទិន្នន័យ ពីអង្គការសង្គ្រោះកុមារ បានឱ្យដឹងថាមានក្មេងៗប្រមាណជា ១០០០០នាក់ ដែលកំពុងធ្វើការនៅតាមផ្លូវ ហើយមាន១០០០នាក់កំពុងរស់នៅតាមផ្លូវនៅក្នុងទីក្រុងភ្នំពេញ។ ភាពក្រីក្រជាកត្តាដ៏ធំមួយដែលនាំឱ្យក្មេងៗផ្លាស់ប្តូរជីវិតរបស់គេរស់នៅតាមផ្លូវ ប៉ុន្តែ ក៏មានកត្តារួមផ្សំផ្សេងៗទៀតដូចជា អំពើហិង្សាក្នុងគ្រួសារ ឬឪពុកម្តាយពួកគេបានបាត់បង់ជីវិតដោយសារមេរោគអេដស៍ជាដើម។ ហេតុផលសំខាន់ដែលធ្វើឱ្យជីវិតរស់នៅបាន គឺកុមារទាំងនោះជារៀងរាល់ថ្ងៃ បានខិតខំធ្វើការក្នុងសកម្មភាពផ្សេងៗ ពីគ្នា ដូចជា ធ្វើពេស្យាចារ ជាចោរកំប៉ិកកំប៉ុក សុំទាន លាងឡានលក់សៀវភៅ លក់ផ្កា ឬក៏លក់កាសែតជាដើម។ ពួកគេមិនអាចទៅសាលាបានឡើយ ដោយសារតែថ្លៃសាលាខ្ពស់ពេក ហើយគ្រួសារពួកគេជារឿយៗ ពឹងផ្អែកទៅលើប្រាក់ចំណូលរបស់ពួកគេ ទោះបីជាមានចំនួនតិចតួចក៏ដោយ។ ប្រជាជនកម្ពុជាជាងពាក់កណ្តាលនៃប្រជាជនប្រមាណ ១៣លាននាក់ មានអាយុក្រោម ១៨ឆ្នាំ ហើយការរកចំណូលរបស់កុមារគឺមិនមានភាពប្រក្រតីទេ។ អង្គការUNESCO កម្ពុជា បានធ្វើការប៉ាន់ប្រមាណថា មានកុមារ ៧០០០០០នាក់ ដែលកំពុងប្រកបការងារ។ ពួកគេមានអាយុពី៥-១៧ឆ្នាំ និងចំនួនជិត៣ភាគ៤នៃក្មេងៗទាំងនេះ បោះបង់ការសិក្សា ឬក៏មិនដែលចូលសាលាឡើយ។ កត្តាដែលនាំឱ្យមានក្មេងៗមាននៅតាមផ្លូវ គឺដោយសារ ជីវភាពក្រីក្រ កំណើនឡើងចំនួនប្រជាជនឆាប់រហ័ស និងការចាកចោលស្រុកកំណើតស្វែងរកការងារធ្វើ និងកត្តាមួយទៀត គឺកង្វះខាតនូវប្រព័ន្ធអប់រំ ការលើកទឹកចិត្តបញ្ឈប់ពលកម្មកុមារ និងឧប្បត្តិហេតុផ្សេងៗទៅលើក្មេងនៅតាមទីផ្លូវ។ មានការប៉ាន់ប្រមាណថា ក្មេងដែលរស់នៅតាមផ្លូវ គឺមានប្រមាណជា ១០៥០នាក់ នៅក្នុងរាជធានីភ្នំពេញ ដែលនៅក្នុងនោះ ក៏មានជាង ៦៧០នាក់ទៀត រស់នៅតាមផ្លូវជាមួយនិងគ្រួសាររបស់ពួកគេ។

**ម៉ាឡេស៊ី**

បើតាមទិន្នន័យស្ថិតិមួយ ដែលអាចយកជាការបាន ចំពោះការស្ទាបស្ទង់ទៅលើកុមាររស់នៅតាមចិញ្ចើមថ្នល់ មានច្រើន គឺនៅចន្លោះពី១០០០០ និង ៣០០០០នាក់។ ម្យ៉ាងទៀត ក្មេងៗដែលរស់នៅតាមផ្លូវទាំងនោះ មានប្រហែល ៨០០០ នាក់ រស់ក្នុងវិទ្យាស្ថានថែរក្សាកុមារនៃប្រទេសម៉ាឡេស៊ី។ (ទិន្នន័យពីអង្គការយូនីសេហ្វ)

## ភាពឯកោ និងការព្យាយាម

អង្គុយនៅលើវាលស្មៅ មានទ្រុងចាបបញ្ឈរនៅពីមុខ ដែលមានចាបជាច្រើនក្បាលនៅក្នុងនោះផងដែរ កុមារាចក់សាន្ត មានសម្បុរខ្មៅស្រអែម ដែលអាចបញ្ជាក់ឱ្យអ្នកដំណើរ និងភ្ញៀវទេសចរអាចវាយតម្លៃថា វាជាក្មេងលក់ចាប។

ចក់ សាន្ត បានចាកចោលផ្ទះកំណើតរបស់គេ នៅស្រុកមោង ខេត្តបាត់ដំបង ប្រហែលជាក្នុងអំឡុងឆ្នាំ២០០០ ដែលពេលនោះ គេក៏បានចូលសិក្សានៅក្នុងមណ្ឌលអង្គការមិត្តសម្លាញ់ផងដែរ។ កុមារាសាន្ត ប្រាប់ឱ្យដឹង ក្រោមទឹកមុខស្រពោន និងសម្លេងមួយៗថា: “ខ្ញុំបានបញ្ចប់ការសិក្សា នៅអង្គការមិត្តសម្លាញ់នៅថ្នាក់ទី៧ ព្រោះលក្ខខណ្ឌអង្គការ ជួយឱ្យបានរៀនត្រឹមថ្នាក់ទី៧ប៉ុណ្ណោះហើយបានអង្គការបញ្ជូនទៅរៀននៅឯស្រុកកំណើតវិញ។ តែដោយសារតែគ្មានលុយរៀនបន្តទៀតទើបខ្ញុំត្រូវឈប់រៀន”។ សាន្ត បន្តឱ្យដឹងទៀតថា ការរស់នៅដោយអង្គការឧបត្ថម្ភ មានភាពងាយស្រួល មិនមានលំបាកអ្វីឡើយ ដោយគេបានទិញកង់ និងរបស់របរផ្សេងៗទៀតឱ្យ។ ក្រោយពីបញ្ចប់ការសិក្សា និងត្រលប់មកពីស្រុកកំណើតវិញ សាន្តបានសម្រេចចិត្តចាប់យកអាជីពជាអ្នកលក់ចាប ដើម្បីសន្សំលុយឱ្យម្តាយ និងចាយវាយខ្លួនឯងផងដែរ ដោយមិនខ្វល់ខ្វាយពីការលំបាកអ្វីទេ។ ចក់ សាន្ត មិនដែលរារែកចិត្ត ក្នុងការបន្តការសិក្សារបស់គេនោះទេ គឺសាន្តនៅតែប្រាថ្នាចង់រៀនជានិច្ច។ “នៅពេលដែលខ្ញុំធំជាងនេះ ខ្ញុំនឹងទៅចូលក្នុងមណ្ឌលរបស់អង្គការមិត្តសម្លាញ់វិញ ដើម្បីរៀនឱ្យក្លាយទៅជាចុងភៅម្នាក់យ៉ាងចំណាន” នេះជាសេចក្តីប៉ងប្រាថ្នារបស់ចក់ សាន្តទៅថ្ងៃអនាគត ដែលកុមារាអាយុ ១៧ ឆ្នាំរូបនេះ មិនចង់លក់ចាបដូច្នេះអស់មួយជីវិតឡើយ។

កុមារាស៊ុន ចាន់ មានអាយុ ១៣ឆ្នាំ ដែលកំពុងជជែកលេងជាមួយមិត្តភក្តិរបស់គេ នៅក្រោមស្តូបមួយ នៅឯវត្តភ្នំបាននិយាយថា: “ខ្ញុំមកទីនេះ ដើម្បីសុំលុយគេយកទិញអាហារហូប”។ ទោះបីជាចាន់មានការលំបាកនៅក្នុងការរកថវិកាក៏ដូចជាលំបាកក្នុងផ្នែកជីវភាពគ្រួសារយ៉ាងណាក៏ដោយ ប៉ុន្តែចាន់ហាក់ដូចជាមានសំណាងជាងកុមារមួយចំនួន ដែលមានវ័យស្មើនឹងចាន់ដែរ ពីព្រោះចាន់មានឱកាសបានរៀនសូត្រ។ មកដល់ពេលនេះ ចាន់រៀនដល់ថ្នាក់ ទី៤ហើយ ដោយមាន...

... ការជួយឧបត្ថម្ភពីអង្គការមិត្តសម្លាញ់។ "ធំឡើងខ្ញុំចង់ក្លាយជាគ្រូពេទ្យ" នេះគឺជាក្តីសង្ឃឹមរបស់កុមារាស៊ុន ចាន់ ដែលទើបតែមានអាយុ ១៣ឆ្នាំប៉ុណ្ណោះ។

ជាមួយនេះដែរ លោកគ្រូបង្រៀនអង់គ្លេស ថុង យ៉ត នៅឯសាលាញូវតុនធីឡាយ ក៏មានចំណាប់អារម្មណ៍ចំពោះករណីនេះថា នៅពេលដែលលោកបានឃើញក្មេងអនាថា ឬក៏ក្មេងសុំទាននៅតាមផ្លូវ ឬតាមរមណីយដ្ឋាននានា លោកមានការអាណិត និងចង់ជួយគេឱ្យបានទៅរៀន ដូចជាប្អូនរបស់គាត់ដែរ។ លោកបន្តថា នៅក្នុងបញ្ហានេះ រាជរដ្ឋាភិបាលជាអ្នកដែលមានកាតព្វកិច្ចជាចម្បងដោយគួរបង្កើតឱ្យមានការងារឱ្យពួកគេធ្វើ ឱ្យបានគ្រប់គ្រាន់ និងធ្វើការទាក់ទាញអ្នកវិនិយោគទុនឱ្យបានកាន់តែច្រើនជាងនេះទៀត។ ប៉ុន្តែលោកពុំមែនផ្តោតតែទៅលើក្មេងអនាថាមួយនោះទេ គឺរួមផ្សំ ទាំងគ្រួសារក្រីក្រ ឬមានជំងឺ និងខ្វះការអប់រំវិជ្ជាជីវៈជាដើម។

យោងតាមការសិក្សារបស់និស្សិតនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញចំពោះបញ្ហាកុមារ តាមចិញ្ចើមថ្នល់ នៅឆ្នាំ២០០៤-២០០៥ បានឱ្យដឹងដែរថា ក្នុងប្រជាជនកម្ពុជាសរុបប្រមាណជា ១០,៣លាននាក់ ក្នុងនោះប្រហែលជា ៥,១លាននាក់ គឺត្រូវជា ៤៩,៥% ជាកុមារក្រោមអាយុ ១៨ឆ្នាំ និងប្រហែល ១៨,២%ជាក្មេងមានអាយុពី៥-១៧ឆ្នាំ ដែលប្រកបការងារចិញ្ចឹមជីវិត។ ចំណែកក្មេងៗ រស់តាមចិញ្ចើមថ្នល់មួយចំនួនទៀត បានលក់ខ្លួនពួកគេទៅឱ្យអ្នកទេសចរក្នុងតម្លៃ ដ៏តិចតួចបំផុត។ លើសពីនេះទៅទៀត កុមារប្រមាណជាង ៤០០នាក់ទៀត ដែលមានអាយុពី៥-១៧ឆ្នាំ កំពុងធ្វើការងារនៅក្នុងទីក្រុងភ្នំពេញ ដូចជាធ្វើការនៅកន្លែងចាក់សំរាម ឬដើររើសសំរាមនៅតាមផ្លូវជាដើម។ ដោយឡែកមានកុមារប្រមាណជា ៣៥%ប៉ុណ្ណោះ ដែលបានចូលសាលារៀន និងភាគច្រើនធ្វើការនៅគំនរសំរាមរយៈពេលជាង ៣ឆ្នាំ។ ពួកគេអាចរកចំណូលបាន ពី២០០០-៤០០០រៀល ក្នុង១ថ្ងៃ។

កុមារៗរស់នៅតាមចិញ្ចើមថ្នល់ក្លាយទៅជាបញ្ហាយ៉ាងជាក់ស្តែងមួយនៅក្នុងតំបន់ទីក្រុងនៃប្រទេសកម្ពុជាតាំងតែពីឆ្នាំ១៩៩០មក។ ភាគច្រើននៃក្មេងទាំងនេះ មកពីខេត្តដើម្បីធ្វើការជួយទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគេ ឬដើម្បីគេចខ្លួនចេញពីអំពើហិង្សា និងភាពក្រីក្រនៅក្នុងគ្រួសារ។

### ប្រទេសថៃ

យោងតាមការវាយតម្លៃជាផ្លូវការបានឱ្យដឹងថា មានក្មេងរស់តាមចិញ្ចើមថ្នល់ចំនួន ១៥០០០នាក់ នៅប្រទេសថៃ ដែលជាង៥០០០នាក់ រស់នៅក្រុងបាងកក និងបើតាមតួលេខនៃរាជរដ្ឋាភិបាលបានឱ្យដឹងថា មានក្មេងសុំទាន ១០៦២នាក់ រស់នៅទីក្រុងបាងកកនាឆ្នាំ១៩៩៩ ដែលក្នុងចំណោមនោះ មាន៨០នាក់ ជាថៃ និង៩៨២នាក់ ជាជនបរទេស។

## លោកបូជាចារ្យតូទិត : "យើងចូលរួមជួយគាំទ្រសកម្មភាពក្មេងដើម្បីប្រយោជន៍របស់ពួកគេ"



Photo: L. Sovanna

លោកបូជាចារ្យតូទិត នៃព្រះសហគមន៍បាត់ដំបងមានប្រសាសន៍ថា ព្រះសហគមន៍បាត់ដំបងមានគម្រោងជួយដល់ក្មេងៗច្រើន ដែលយើងចាប់ផ្តើមធ្វើតាំងពីឆ្នាំ២០០៥ ដោយយើងបានទាក់ទងជាមួយយុវជន ដែលនៅខាងក្រៅឱ្យដើរតាមដានក្មេងអនាថា ដែលសុំទានតាមភោជនីយដ្ឋាន ដេកក្រោមស្ពាន និងគ្មានផ្ទះសម្បែងជាដើម។ យើងក៏បានប្រមូលគេឱ្យមករៀន និងឱ្យគេមានអារម្មណ៍ថា យើងថែរក្សាគេ ទទួលខុសត្រូវអំពីគេ ដែលនេះជាកម្មវិធីដ៏ជោគជ័យល្អមែនទែន។ នៅជារៀងរាល់ថ្ងៃអាទិត្យ យើងប្រមូលក្មេងទាំងនោះមកព្រះសហគមន៍ដើម្បីបង្រៀនពួកគេ ឱ្យចេះរាំ មានសីលធម៌ល្អ ចេះពីទំនៀមទម្លាប់ខ្មែរ និងចេះសហការគ្នាជាដើម។ ក្នុងនាមយើងជាព្រះសហគមន៍ យើងគួរចូលរួមជួយពួកគេដោយធ្វើការគាំទ្រនូវកម្មវិធីដែលជួយដល់ក្មេងទាំងនោះ តាមរយៈអង្គការព្រះសហគមន៍ផ្សេងៗដូចជាការីតាស និងម៉ារីណុលជាដើម ដែលនេះជារបៀបដែលយើងចូលរួមជួយគាំទ្រសកម្មភាពដើម្បីជាប្រយោជន៍របស់កូនក្មេង និងការគាំទ្រកូនក្មេងតាមរយៈអង្គការរបស់ព្រះសហគមន៍កាតូលិក។ ចំពោះកូនក្មេងដែលមិនបានទៅសាលារៀន គឺធ្វើឱ្យមានការប៉ះពាល់ខ្លាំងដល់អនាគតរបស់ប្រទេសជាតិ។ បើកូនក្មេងល្ងង់មិនចេះ ប្រទេសជាតិនោះនឹងមានជួបផលលំបាកនៅពេលខាងមុខ។ ដូច្នេះយើងត្រូវធ្វើការជួយគាំទ្រដល់កុមារដោយជួយបង្រៀនពួកគេឱ្យចេះអក្សរដើម្បីជាប្រយោជន៍ដល់ក្រុមគ្រួសារ និងប្រយោជន៍ប្រទេសជាតិនោះផងដែរ។

ក្នុងនោះដែរ លោកគឹម ហៀង មកពីសមាគមនិស្សិតស្ទួន សុវណ្ណកុមារ បានមានមតិខ្លះៗដែរថា ការបង្ខំឱ្យកូនធ្វើការក្នុងអំឡុងពេលសិក្សា ដូចជាឱ្យដើររើសអេតចាយជាដើម វានឹងធ្វើឱ្យមានការប៉ះពាល់ដល់សុខភាព និងការសិក្សារបស់គេ ដូចជាអាចធ្វើឱ្យក្មេងនោះឆ្លងជំងឺតាមរយៈដៃ ពិសេសពេលញ៉ាំអាហារដោយមិនបានលាងដៃ។ល។ ប៉ុន្តែការបង្ខំកូនឱ្យធ្វើការនេះ មិនមែនជាកំហុសរបស់ឪពុកម្តាយទាំងស្រុងនោះទេ ព្រោះឪពុកម្តាយណាក៏ចង់ឱ្យកូនរបស់ខ្លួនមានអនាគតល្អដែរ ប៉ុន្តែដោយសារបញ្ហាជីវភាពនៅចំពោះមុខ ទើបគាត់បង្ខំចិត្តប្រើកូនរបស់គាត់ឱ្យជួយរកលុយបន្ថែមដើម្បីទ្រទ្រង់ក្នុងជីវភាពគ្រួសាររបស់គាត់។

អត្ថបទដោយមុំ គន្ធា និងសុជាតិ





នាថ្ងៃទី១៥ មីនា ២០០៧ នៅព្រះសហគន៏កំពត មានផ្តល់នូវសមិទ្ធផលថ្មីរបស់ខ្លួនមួយទៀតជូនដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋជុំវិញខេត្ត ដែលនេះជាការចូលរួមចំណែកដ៏ធំមួយទៀតនៃព្រះសហគមន៏កាតូលិកក្នុងកិច្ចការអភិវឌ្ឍន៏ប្រទេស។

# អំណរសប្បាយនឹងសមិទ្ធផលថ្មី



លោកអភិបាលប្រគល់បណ្ណសរសើរជូនសប្បុរសជន

Photo: L. Sovanna

"មជ្ឈមណ្ឌលវប្បធម៌កាតូលិកកំពត" ជាអគារដ៏ថ្មីស្រឡាងមួយដែលបានសម្ពោធ ដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅភូមិសុវណ្ណសាគរ ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពតក្រោមការចូលរួមដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមសូត យ៉ា អភិបាលរងខេត្តកំពត លោកអភិបាលអេមីល ដេតម្ប លោកបូជាចារ្យអូលីវីយេ លោកបូជាចារ្យ បងស្រី ប្រជាពលរដ្ឋ សិស្សានុសិស្ស ភ្ញៀវជាតិ និងអន្តរជាតិជាច្រើនរូបទៀត ដែលសរុបមានប្រមាណជាជាង ២០០នាក់។

ក្រោយពីលោកអភិបាលអេមីល ដេតម្ប បានធ្វើពិធីបាចទឹកព្រះពរជូនឱ្យដល់ភ្ញៀវ និងបាចនៅគ្រប់បន្ទប់ទាំងអស់របស់អគាររួចមក អង្គពិធីទាំងមូលបានចាប់ផ្តើមឡើងដោយមានការគោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា និងការជូនរបាយការណ៍ពីលោកនាយកមជ្ឈមណ្ឌលវប្បធម៌កាតូលិកទៀតផងដែរ។ នាឱកាសដ៏វិសេសវិសាលនោះ លោកបូជាចារ្យអូលីវីយេ ដែលជាអ្នកសម្របសម្រួលមជ្ឈមណ្ឌលមានប្រសាសន៍ថា: "នៅថ្ងៃនេះ យើងបានធ្វើការសម្ពោធមជ្ឈមណ្ឌលវប្បធម៌កាតូលិក ដែលជាមណ្ឌលមួយ ដើម្បីទទួលយកកុមារាកុមារី និងយុវជន-នារី ដែលចង់រៀនបន្ថែមយកចំណេះដឹងភាសាអង់គ្លេស កុំព្យូទ័រ និងវប្បធម៌ទូទៅ-ល-។ មជ្ឈមណ្ឌលវប្បធម៌នេះនឹងទទួលស្វាគមន៍ដល់បងប្អូនទាំងអស់ដោយមិនប្រកាន់វណ្ណៈ ពូជសាសន៏ ឬសាសនាឡើយ"។ លោកបន្តទៀតថា កូនៗខ្មែរមានចំណង់ ចង់រៀនសូត្រច្រើន ព្រោះពួកគេចង់ចេះដឹង។ នេះគឺជាការល្អប្រសើរបំផុតដើម្បីជួយឱ្យប្រទេសកម្ពុជាកាន់តែរីកចម្រើនខ្លាំងឡើងៗ។

ទោះបីនឿយហត់យ៉ាងណាក៏ដោយ លោកអេមីល ដេតម្ប អភិបាលនៃភូមិភាគភ្នំពេញ នៅតែមានទឹកមុខញញឹមជាប់ជានិច្ចដោយបានឃើញនូវសមិទ្ធផល យ៉ាងត្រចេះត្រចង់នេះ ហើយលោកបានសូមអរគុណម្ចាស់ជំនួយទាំងអស់និងចងចាំជានិច្ចនូវកិច្ចសហប្រតិបត្តិការនេះ។

ជាមួយនេះផងដែរ លោកសូត យ៉ា អភិបាលរងខេត្តកំពត ក៏បានឡើងមានមតិសំណេះសំណាលនៅក្នុងទិវានោះ និងបានថ្លែងអំណរគុណ ព្រមទាំងបានកោតសរសើរចំពោះសប្បុរសជនទាំងនៅក្នុង និងក្រៅប្រទេសទាំងអស់ដែលបានចំណាយថវិកាផ្ទាល់ខ្លួនដើម្បីកសាងមជ្ឈមណ្ឌលកាតូលិកកំពតនេះ។ ក្នុងខណៈនោះដែរ លោកបានស្នើសុំឱ្យមជ្ឈមណ្ឌលវប្បធម៌នេះគោរពទៅតាមនិយាមនៃក្រសួងអប់រំយុវជន និងកីឡា ដើម្បីជួយធ្វើឱ្យវិស័យអប់រំ នៅប្រទេសកម្ពុជា កាន់តែមានការរីកចម្រើនថែមមួយកម្រិតទៀត។

លោកគ្រូទួន សុធា អ្នកទទួលខុសត្រូវមជ្ឈមណ្ឌលនេះ បានឱ្យដឹងអំពីគោលបំណងក្នុងការបង្កើតមណ្ឌលនេះថា គឺដើម្បីចូលរួមចំណែកលើកស្ទួយវិស័យវប្បធម៌សិល្បៈខ្មែរ និងជួយបណ្តុះបណ្តាលធនធានមនុស្សនៅប្រទេសកម្ពុជា។ លោកក៏បន្ថែមទៀតថា សម្រាប់ទិសដៅនៅពេលខាងមុខ យើងនឹងត្រៀមរៀបចំនូវសកម្មទាំងអស់របស់មជ្ឈមណ្ឌល ដែលជាប្រយោជន៍ដើម្បីបំរើឱ្យដល់បងប្អូនសិស្សានុសិស្ស និងមហាជនទូទៅ ក៏ដូចជាសង្គមជាតិទាំងមូល ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ឬសាសនាអ្វីមួយឡើយ។

យុវជនតូច ញឿនបានប្រាប់ដែរថា មជ្ឈមណ្ឌលនេះនឹងផ្តល់អត្ថប្រយោជន៍ច្រើនសម្រាប់ទាំងសិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងខេត្តកំពតនេះ ព្រោះពួកគេបានសាលាល្អ និងនៅជិតផ្ទះ ដែលនេះនឹងធ្វើឱ្យរីកចម្រើនដល់ខេត្តផងដែរ។

មុំ គន្ធា

### មជ្ឈមណ្ឌលវប្បធម៌កាតូលិកខេត្តកំពត

បានចាប់ផ្តើកកសាងឡើងចាប់ពីខែកុម្ភៈ ដល់ខែធ្នូ ឆ្នាំ២០០៦ ដែលជាអគារមួយខ្នង មានកម្ពស់ ២ជាន់ ស្មើនឹង ៩បន្ទប់ ដែលមានដូចជាបន្ទប់ការិយាល័យ បន្ទប់ធ្វើម្ហូប បន្ទប់សិក្សាភាសាអង់គ្លេស បន្ទប់កុំព្យូទ័រ បណ្ណាល័យ និងបន្ទប់ស្តាប់ភាសា។ មជ្ឈមណ្ឌលនេះបានសាងសង់ឡើងដោយចំណាយថវិកាអស់ចំនួន ៨ម៉ឺនដុល្លារ ដែលនៅក្នុងនោះជំនួយមកពីសប្បុរសជនជប៉ុន មានចំនួន ៥២០០០ដុល្លារ និងជំនួយមួយចំនួនទៀតបានទទួលការជួយឧបត្ថម្ភពីព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាយើង។

នៅស្ទើរគ្រប់ព្រះសហគមន៍កាតូលិកតែងមានរបាំប្រចាំខ្លួន ជាមួយនេះដែរព្រះសហគមន៍ទាំងបីភូមិភាគបានរួមគ្នាបង្កើតនូវរបាំមួយ ដែលមានឈ្មោះថា "របាំសន្តិភាព" គឺក្នុងន័យព្រះសហគមន៍។

# របាំសន្តិភាព


Photo: P. Samphy

ព្រះសហគមន៍យកចិត្តទុកដាក់បង្រៀនរបាំជួយពង្រឹងវប្បធម៌

កញ្ញាសួន ប៊ុណ្ណារ៉េត ហៅស្រីមុំ ជាគ្រូរបាំនៅបឹងទំពុន មានប្រសាសន៍ឱ្យដឹងអំពីរបាំសន្តិភាពទាក់ទងនឹងព្រះសហគមន៍ថា: "របាំនេះសម្ដែងក្នុងន័យរួបរួមសាមគ្គីគ្នា ទំនាក់ទំនងគ្នានិងគ្នា ពីព្រះសហគមន៍មួយ ទៅព្រះសហគមន៍មួយ"។

អ្នកគ្រូដែលមានបទពិសោធន៍ តាំងពីអាយុ១៥ឆ្នាំ រហូតមកដល់ពេលនេះ បានបន្តទៀតថា របាំនេះ អ្នកគ្រូបង្កើតឡើងគឺចង់បង្ហាញថាព្រះសហគមន៍យើងរួមជាធ្លុងមួយ មិនប្រកាន់ ឬរើសអើងវណ្ណៈឡើយ។ របាំសន្តិភាព គឺមាន ៣វគ្គ សេចក្ដីស្រលាញ់ ពិភពលោក និងព្រះអង្គប្រទាននូវអំណោយទាននេះដល់យើងម្នាក់ៗ ហើយយើងក៏បង្ហាញទៅគ្នាទៅវិញទៅមក។ នៅក្នុង ៣វគ្គនេះ គឺមាន ៥ក្បាច់ តាំងពីការដើរចេញមក ដែលបញ្ជាក់ឱ្យឃើញនូវការជឿជាក់របស់យើងម្នាក់ៗដែលបានធ្វើ និងបង្ហាញអំពីសកម្មភាពរបស់ពួកយើងដូចជាការកោតសរសើរព្រះអង្គ ដែលបានប្រទានពិភពលោកដល់យើង។ ព្រះអង្គប្រទាននូវសេចក្ដីស្រលាញ់ដល់យើង ហើយយើងចែកដល់អ្នកដទៃមិនថា ស្រី ឬប្រុស ចាស់ ឬក្មេងទេ។ របាំសន្តិភាពនិយមសម្ដែងនៅក្នុងកម្មវិធីធំៗ ដូចជាពិធីតែងតាំងលោកអភិបាល លោកបូជាចារ្យ ឬមួយបងស្រីជាដើម។

## ការកកើតរបាំ

ដោយសារព្រះសហគមន៍កាតូលិកមានកំណើតរាប់រយឆ្នាំមកហើយនៅក្នុងប្រទេសកម្ពុជា ជាហេតុនាំឱ្យព្រះសហគមន៍មានគំនិតបង្កើតរបាំនេះឡើងរួមគ្នាទាំងបីភូមិភាគ ដើម្បីជាតំណាងក្នុងការរួបរួមសាមគ្គីជាធ្លុងមួយប្រកបដោយសន្តិភាព រៀងរហូតជានិរន្តរ៍។ របាំសន្តិភាពនេះបង្កើតតាមរយៈក្បាច់ខ្មែរផង ឱ្យស៊ីជំរៅទៅនឹងអត្ថបទរបស់ព្រះសហគមន៍ផង។

ការបង្ហាត់របាំសន្តិភាពនេះ ត្រូវចម្រាញ់យកអ្នក ដែលហាត់របាំបុរាណ ដែលនេះមានភាពងាយស្រួល ក្នុងការបង្ហាត់ពួកគេ។ អ្នកសម្ដែងរបាំនេះតម្រូវឱ្យមានអ្នកសម្ដែងច្រើន ចាប់ពី៣០-៥០នាក់ និងតិចបំផុត ក៏១៥នាក់ដែរ និងរយៈពេលសម្ដែង គឺមានរយៈពេល ១០នាទីតែប៉ុណ្ណោះ។

តាមធម្មតាអ្នកសិល្បៈ មុននឹងសម្ដែង ត្រូវថ្វាយភ្លេងពិណ-ពាទ្យរំឭកដល់អារក្សអ្នកតា និងអុជធូបដើម្បីឱ្យការសម្ដែងបានល្អ តែសម្រាប់ព្រះសហគមន៍កាតូលិក ហាក់ដូចជាមានការប្រទានពរពីព្រះជាម្ចាស់ដែលធ្វើឱ្យការសម្ដែងមានភាពរលូន។ ទោះបីជាដូច្នេះរបាំនេះតម្រូវឱ្យមានភ្លេងពិណពាទ្យគ្រប់សព្វនៅពេលសម្ដែង។ អ្នកសម្ដែងត្រូវស្លៀកពាក់អាវណយស ចងក្បិនពណ៌កាប់ស្ពាំង មានកាន់ផ្តិត និងសក់ក៏បួងលាវធម្មតា។ អ្នកចង់ក្លាយខ្លួនជាអ្នករបាំគឺត្រូវមានលក្ខណៈជាស្ត្រីខ្មែរ រាងស្គម និងមានឧបនិស្ស័យពីធម្មជាតិ ដែលនេះងាយស្រួលក្នុងការហាត់ តែត្រូវចំណាយរយៈពេលយូរ។

មុំ គន្ធា



# ល្បងចិញ្ចឹមកង្កែប

កង្កែបមានរសជាតិឆ្ងាញ់ និងតម្លៃថ្លៃ។ កង្កែបលក់លើទីផ្សារ ភាគច្រើនគឺប្រជាកសិករចាប់នៅតាមវាលស្រែ។ ប្រសិនបើកសិករអាចចិញ្ចឹមវិញនោះ នឹងធ្វើឱ្យជីវភាពគ្រួសារគាត់បានល្អប្រសើរ។


Photo: DR

ទ្រុងត្រូវធ្វើរបងកៅស៊ូប្លាស្ទិកព័ទ្ធជុំវិញការពារកុំឱ្យកង្កែបលោតចេញ

លោករាជ សុភាព អនុបណ្ឌិតផ្នែកវារីវប្បកម្ម និងផលិតពូជនៃអង្គការសេដាក បានបង្ហាញនូវបទពិសោធន៍ពីការចិញ្ចឹមកង្កែបដូចតទៅ:

យើងចាប់កូនកង្កែប នៅជុំវិញតំបន់រស់នៅ។ ដើម្បីឱ្យងាយស្រួល ចាប់ចិញ្ចឹមកង្កែប នៅពេលវានៅជាកូន ពាកតូចៗ។ ដាក់កង្កែបចិញ្ចឹមក្នុងស្នូនទំហំប៉ុនៗគ្នា ដើម្បីកុំឱ្យវាលេបស៊ីគ្នា។ កុំចាប់កង្កែបអាចម៍គោ ព្រោះចិញ្ចឹមមិនធំទេ។

កន្លែងចិញ្ចឹមត្រូវតែជាទីវាលស្រឡះ គឺមិនមានលិចទឹកនៅរដូវវស្សា ស្ងប់ស្ងាត់ និងគ្មានមនុស្សចេញចូល អ៊ូអរ។ សូមឱ្យរៀបចំស្នូនមួយ ដែលមានបណ្ដោយ ៥ម៉ែត្រ និងទទឹង ៣ម៉ែត្រ។ ដាំបង្គោលឬស្សីជារបង និងព័ទ្ធជុំវិញ ដោយកៅស៊ូប្លាស្ទិក រួចយកធាងត្នោតគាបពីក្រៅការពារកុំឱ្យសត្វជ្រូកឬសត្វអ្វីផ្សេងៗឈ្លុលចូល។ នៅក្នុងស្នូន សូមជីករណ្ដៅ ដែលមានបណ្ដោយ ៥ម៉ែត្រ ទទឹង ១,២ម៉ែត្រ និងជម្រៅ ៥តឹក។ បន្ទាប់ពីក្រាលកៅស៊ូប្លាស្ទិកពាសនៅបាតរណ្ដៅរួច ដាក់ភក់កម្រាសមួយតឹក។ រួចហើយដាក់ទឹកបំពេញរណ្ដៅ ដើម្បីឱ្យកង្កែបបន្ទើមស្បែក។ នៅក្នុងស្នូន យើងអាចដាំជាស្លឹកគ្រៃពពាយជ្រុង ជីគ្រប់មុខ សម្រាប់ទុកបរិភោគ និងពួកវាអាចជាកន្លែងបង្កើតសត្វល្អិតដែលជាចំណីរបស់កង្កែប។

ចាប់ចិញ្ចឹមនៅដើមរដូវវស្សា។ សូមដាក់កូនកង្កែប ១២០០ កូនទៅក្នុងស្នូនប៉ុនៗគ្នា ប៉ុនមេដៃ។ ក្រាលប្លាស្ទិក បណ្ដោយ ៤ម៉ែត្រ និងទទឹង២ម៉ែត្រ ទុកជាកន្លែងដាក់ចំណី។ សូមដាក់ចំណីនៅពេលព្រលប់ សប្ដាហ៍ដំបូង ១ថ្ងៃ ដាក់ជន្លេន ៣គីឡូក្រាម។ សប្ដាហ៍ទី២ បន្ថែមបាយមួយចានគោម និងសប្ដាហ៍ទី៣ ដាក់ចំណីគ្រប់មុខ ដូចជា ជន្លេន ក្ដាម អាចម៍ត្រី បាយលាយចូលគ្នាពី ៣-៤គីឡូក្រាម ក្នុង១ថ្ងៃ។ ពេលដាក់ចំណីត្រូវគោះចានឱ្យឮសម្លេងដើម្បីកង្កែបចេញមកស៊ី។ ចូរដាក់អំពូលភ្លើងដើម្បីទាក់ទាញសត្វល្អិតជាចំណីបន្ថែមកង្កែប។

សូមឧស្សាហ៍ផ្លាស់ប្ដូរទឹកក្នុងរណ្ដៅ សម្អាតកន្លែងដាក់ចំណី និងពិនិត្យជុំវិញស្នូន ក្រែងមានសត្វបំផ្លាញរបង ដែលធ្វើឱ្យកង្កែបលោតចេញ។ បើចិញ្ចឹមបានបីខែ កង្កែបលូតលាស់ល្អ ៦ក្បាល មានទម្ងន់ ១គីឡូក្រាម។ សូមលែងកង្កែបខ្លះទៅក្នុងព្រៃធម្មជាតិ ឱ្យបង្កកូនសម្រាប់ធ្វើពូជនៅឆ្នាំក្រោយ។

ផាត សំភី

## កន្លែងសិក្សា

បើប្រិយមិត្តចង់សិក្សាអំពីបច្ចេកទេសនៃការចិញ្ចឹមកង្កែប ត្រី អន្ទង់ ឬជន្លេន-ល- គឺមានបង្រៀននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជានៃអង្គការសេដាក។ ប្រិយមិត្តក៏អាចអញ្ជើញអ្នកជំនាញសេដាក ទៅបង្រៀនដល់ទីកន្លែងក្នុងតម្លៃសមរម្យ។ សូមទំនាក់ទំនងទូរស័ព្ទ : ០១៦ ៦៣៦ ៨៧១ ឬ ០១១ ៨៥៧ ៩៤៩។



# ជំងឺថ្លើម C

ជំងឺថ្លើមមានច្រើនប្រភេទ តែជំងឺថ្លើមប្រភេទសេ គឺជាជំងឺដ៏កាចសាហាវ និងតែងតែផ្ដល់គ្រោះថ្នាក់ធ្ងន់ធ្ងរដល់អ្នកជំងឺដែលធ្លាប់មិនចាប់អារម្មណ៍ និងមិនដឹងអំពីរបៀបវាចម្លងយ៉ាងដូចម្ដេច?

ជំងឺថ្លើមសេ បង្កឡើងដោយមេរោគ ជាវីរុសម្យ៉ាង ដែលធ្វើឱ្យថ្លើមរលាក។វីរុសថ្លើមសេមានឈ្មោះ ជាវិទ្យាសាស្ត្រ ថា អេប៉ាទិត វីរ៉ាល់ សេ (Hépatite virale C) ឬ (HVC)។

ជំងឺថ្លើមប្រភេទសេនេះ ឆ្លងតាមរយៈឈាម និងការរួមរក្សដោយមិនបានការពារ។ ពេលមានមេរោគវីរុសសេនេះ នៅក្នុងខ្លួន រោគសញ្ញាដែលបញ្ចេញមកក្រៅមានដូចជា ក្ដៅខ្លួនអស់កម្លាំង ឬលឿងភ្នែក-ល-។ ហើយរោគសញ្ញានេះ ជួនកាលមិនបានបញ្ចេញឱ្យឃើញអ្វីទាំងអស់។

ជំងឺថ្លើមប្រភេទសេនេះអាចវិវត្តចេញជា២ជំហាន។ ជំហានទី១ ជំងឺមានលក្ខណៈស្រួចស្រាវ អ្នកជំងឺមានរោគសញ្ញាឱ្យដឹងលឿន។ ក្នុងដំណាក់កាលនេះ អ្នកជំងឺអាចជាសះស្បើយ ១៥% ដោយសារការព្យាបាល ហើយជំហានទី២ នោះ មាន ៨៥% ជំងឺអាចវិវត្តទៅជាជំងឺថ្លើមរ៉ាំរ៉ៃ ដែលនៅចុងក្រោយអាចធ្វើឱ្យអ្នកជំងឺកើតទាចទឹក (ជំងឺធំពោះ) ឬជំងឺមហារីកថ្លើម ដែលមានដល់ទៅ៦៥%នៃករណី។ នៅពេលនោះ អ្នកជំងឺគឺអាចទទួលរងគ្រោះថ្នាក់បាត់បង់ជីវិតបាន។

ការព្យាបាលជំងឺថ្លើមសេ ដែលជាជំងឺបង្កឡើងដោយវីរុស គឺត្រូវព្យាបាលទៅតាមរោគសញ្ញារបស់វា។ បើក្ដៅខ្លួន យើងព្យាបាលក្ដៅខ្លួន។ យើងចាក់ថ្នាំណាដែលអាចឃាត់វីរុស កុំឱ្យចំនួនវាកើនឡើង។ ដូច្នេះសំខាន់ អ្នកជំងឺគឺត្រូវតែមកជួបជាមួយនិងវេជ្ជបណ្ឌិតជំនាញ។

នៅកម្ពុជាជំងឺថ្លើមប្រភេទសេ ច្រើនតែកើតមានលើមនុស្សចាស់ដែលមានអាយុពី ៣០ឆ្នាំ ឡើងទៅ ហើយមានតែការពិនិត្យឈាមទេដែលអាចកំណត់បានថា យើងមាន ឬក៏គ្មានជំងឺនេះ។ បើយើងឆាប់ដឹង យើងក៏ងាយទប់ស្កាត់ តាមដាន និងព្យាបាលចំពោះជំងឺនេះ។ ម្យ៉ាងទៀតយើងក៏អាចថែទាំសុខភាព និងការពារកុំឱ្យចម្លងទៅអ្នកដទៃផងដែរ។

ផាត សំភី


Photo: P. Samphy

វេជ្ជបណ្ឌិតឈៀវ គន្ធារី នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

## ការការពារខ្លួន

ជំងឺថ្លើមប្រភេទសេ ឆ្លងដូចជំងឺអេដស៍ដែរ។ ដូច្នេះយើងកុំប្រើម្ជុល ឬស៊ីរ៉ាំងមិនស្អាតប្រឡាក់ឈាមមានវីរុសថ្លើមសេចាក់ទម្លុះស្បែក។ បើមានដៃគូរួមរក្សច្រើន យើងត្រូវប្រើស្រោមអនាម័យ។

# អ្នកគ្រូមុំ សារី : "ព្រះវិហារគឺប្រៀបបានដូចជាផ្ទះរបស់ខ្ញុំ"



អ្នកគ្រូមុំ សារី ជាងដេរនៅព្រះសហគមន៍កំពង់ធំ

Photo: L. Sovanna

**សុភាសិតមួយពោលថា : "ជីវិតជាការតស៊ូ" មានមនុស្សភាគច្រើនគោរពតាមសុភាសិតនេះ តែក៏មានមួយចំនួនមិនធ្វើតាម ជាហេតុនាំឱ្យជីវិតជួបការលំបាក។**

---

នេះក៏អាចនិយាយបានថា បំណងប្រាថ្នារបស់ស្ត្រីម្នាក់ ដែលប្រកបទៅដោយការតស៊ូ បានសម្រេចពាក់កណ្ដាលឬស្ទើរតែទាំងអស់។អ្នកគ្រូកាត់ដេរ មុំ សារី នៅឯព្រះសហគមន៍កំពង់ធំ មានការតស៊ូក្នុងជីវិត ដោយមិនមានការត្អូញត្អែរអ្វីបន្តិចសោះឡើយ ទោះបីជាអ្នកគ្រូជាស្ត្រីមេម៉ាយ ដែលដើរតួជាម្ដាយផងនិងជាឪពុកផងរបស់កូន៤នាក់ នៅក្នុងបន្ទុកតាំងពីឆ្នាំ១៩៩៥មក។

អង្គុយនៅលើសាឡុងឈើក្នុងព្រះវិហារកាតូលិកកំពង់ធំអ្នកគ្រូមានប្រសាសន៍ឱ្យដឹងថា: "សព្វថ្ងៃនេះ ខ្ញុំជាមេជាងកាត់ដេរកាបូបនៅក្នុងព្រះវិហារនេះ"។ អ្នកគ្រូក៏បន្តដោយទឹកមុខញញឹមថា នៅក្នុងការមើលថែសិស្សនិងជាគ្រូផងនោះ អ្នកគ្រូគឺតែងតែលំបាក ដោយសារពួកគេហាក់ដូចជា ចានក្នុងរាវ ដែលតែងមានការប៉ះទង្គិចគ្នា បន្តិចបន្តួចជាដើម។ ប៉ុន្តែកត្តាទាំងនេះវាមិនមែនជាភារកិច្ចដែលជាផលលំបាកខ្លាំង សម្រាប់អ្នកគ្រូនោះទេ។

អ្នកគ្រូចេះកាត់ខោអាវដោយសារគាត់មើលតាមម្ដាយ និងមីងរបស់គាត់ រហូតធ្វើឱ្យគាត់ចេះដេរដោយខ្លួនឯង ហើយដោយរួមផ្សំនឹងនិស្ស័យចូលចិត្តកាត់ដេរ ជាពិសេសមានការរៀនបំប៉នបន្ថែមក្រោមការជួយជ្រោមជ្រែងពីលោកបូជាចារ្យផងនោះ ធ្វើឱ្យអ្នកគ្រូកាន់តែមានភាពប៉ិនប្រសប់ក្នុងការកាត់ដេរនេះ និងកាន់តែប្រសើរឡើង។

នៅពេលដែលអ្នកគ្រូមានវ័យចាស់ ហើយពុំអាចដេរបាន អ្នកគ្រូនឹងធ្វើអ្វីផ្សេងវិញ តែគំនិតរបស់អ្នកគ្រូ គឺចង់ឱ្យមានកូនណាម្នាក់របស់អ្នកគ្រូចេះដេរដូចអ្នកគ្រូដែរ ប៉ុន្តែកូនរបស់គាត់ គ្មាននរណាម្នាក់ចង់ដេរដូចគាត់ទេ។ គាត់បានបន្តថា អ្នកគ្រូនឹងលក់ដូរបន្តិចបន្តួចនៅឯផ្ទះ ចិញ្ចឹមសត្វ និងធ្វើស្រែ នេះជាគម្រោងទៅថ្ងៃអនាគត ដែលអ្នកគ្រូដ៏ស្លូតត្រង់ម្នាក់នេះ បានរៀបចំទុកសម្រាប់ជីវិតរបស់គាត់រួចជាស្រេចហើយនោះ។

ដោយសារទឹកចិត្តស្រលាញ់ អ្នកគ្រូស្ម័គ្រចិត្ត បំរើព្រះសហគមន៍គ្រប់ពេលវេលា ទោះបីជាមាន ឬគ្មានប្រាក់បៀវត្សរ៍ក៏ដោយ។ ក្នុងសភាពបែបនេះអ្នកគ្រូមានប្រសាសន៍ខ្លាំងៗថា : "យើងជាគ្រីស្តបរិស័ទ ដោយសេចក្ដីស្រលាញ់ ចិត្តរបស់ខ្ញុំបានបិត នៅក្នុងព្រះវិហារដែលប្រៀបដូចជាផ្ទះរបស់ខ្ញុំដែរ ទោះបីជាខ្ញុំទៅដល់ណា ខ្ញុំនៅតែនឹកឃើញដល់ព្រះវិហារជានិច្ច"។ អ្នកគ្រូវ័យ៤៧ឆ្នាំរូបនេះបន្ថែមទៀតថា គាត់ចង់ស្ដាប់នូវព្រះបន្ទូលឱ្យបានច្រើន។ ម្យ៉ាងអ្នកគ្រូក៏ហាក់ដូចជាមានការស្ដាយក្រោយនឹងជីវិត ឬអ្វីៗដែលកើតមានឡើងចំពោះគាត់បន្តិច ដោយអ្នកគ្រូនិយាយថា : "ប្រសិនបើខ្ញុំមានសមត្ថភាពទាញពេលវេលាថយក្រោយបានខ្ញុំនឹងបួស ពីព្រោះខ្ញុំស្រលាញ់អ្នកបួស។អ្នកបួសមានសមានចិត្ត តែបើយើងមិនបានបួស ក៏មិនថ្វីឱ្យតែយើងមានចិត្តបរិសុទ្ធជួយព្រះសហគមន៍"។

មុំ គន្ធា

## ព្រឹត្តិការណ៍សំខាន់ !

- ថ្ងៃទី០៧ មេសា : បុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង។
- ថ្ងៃទី០៧ មេសាដដែល : បងប្អូនទទួលអគ្គសញ្ញាជ្រមុជទឹកនារាត្រីថ្ងៃបុណ្យចម្លងដែលមាន ៨២នាក់ ពីភូមិភាគភ្នំពេញ ៦១នាក់ ពីភូមិភាគកំពង់ចាម និង២៤នាក់ទៀត មកពីភូមិភាគបាត់ដំបង។
- ថ្ងៃទី១០ មេសា : ព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច) ភ្នំពេញ ចែកអំណោយដល់បងប្អូនគ្រួសារក្រីក្រចំនួន ១០០គ្រួសារ នៅវេលាម៉ោង ៩ព្រឹក ដើម្បីអបអរសាទរចំពោះបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង និងពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ។
- ថ្ងៃទី១៤-១៦ មេសា : ពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ។
- ថ្ងៃទី១៥ មេសា : មានពិធីអរព្រះគុណព្រះជាម្ចាស់ ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ វេលាម៉ោង ៩ព្រឹក ដែលប្រារព្ធធ្វើឡើងនៅព្រះវិហារសន្តយ៉ូសែប។
- ថ្ងៃទី២២ មេសា : សិក្ខាសាលាគ្រូអប់រំជំនឿកូនក្មេងចំនួន ៣០នាក់ នៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) និងព្រះសហគមន៍បឹងទំពុន។
- ថ្ងៃទី២៤-២៧ មេសា : បងប្អូនគ្រីស្តបរិស័ទពន្លកថ្មីចំនួន ១៣នាក់ នៅព្រះសហគមន៍ខេត្តកំពង់ធំ រៀបចំធ្វើពិធីសំណាក់ធម៌ និងរិះគិតពីការរស់នៅជាគ្រីស្តបរិស័ទរយៈពេលមួយឆ្នាំកន្លងមកនៅព្រះសហគមន៍ក្រុងព្រះសីហនុ។
- ថ្ងៃទី២៦ មេសា : ការសម្ពោធសាលាបឋមសិក្សា ពីថ្នាក់ទី១ ដល់ទី៤ និងសាលាមត្តេយ្យ ៣កម្រិត របស់សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈដុនបូស្កូនារីទឹកថ្លា។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៩២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ អូមែរ ហ្សឺរ៉ាល់ដូ